 STATE OF CALIFORNIA - HEALTH AND HUMAN SERVICES AGENCY

# ច្បាប់ថ្មីក្នុងឱកាសការងារនៅ CALIFORNIA និងការទទួលខុសត្រូវចំពោះកុមារ (CALWORKS) សម្រាប់សុវត្ថិភាព និងករណីសម្រាប់តែកុមារ

**ច្បាប់ការគាំទ្រកុមារបានផ្លាស់ប្តូរសម្រាប់គ្រួសាររបស់អ្នក។** អ្នកទទួលបានជំនួយជាសាច់ប្រាក់ CalWORKs សម្រាប់តែកូន (ច្រើននាក់) របស់អ្នកប៉ុណ្ណោះ។ ខាងក្រោមនេះជាការផ្លាស់ប្តូរដែលអនុវត្តចំពោះអ្នក៖

- អ្នកមិនត្រូវឲ្យ "ប្រគល់" សិទ្ធិគាំទ្រកូនរបស់អ្នកទាំងមូលទៅឲ្យខោនធីទេ ប៉ុន្តែនៅតែមានប្រយោជន៍សម្រាប់អ្នកនិងកូន (ច្រើន) របស់អ្នកដោយទទួលបានការគាំទ្រពីភ្នាក់ងារគាំទ្រកុមារក្នុងមូលដ្ឋាន (Local Child Support Agency, LCSA) ក៏ដោយ
- ចំនួនទឹកប្រាក់ដែលអ្នកផ្តល់ឲ្យមិនត្រូវបានផ្លាស់ប្តូរទេឡើយ ប្រសិនបើអ្នកមិនចង់បានសេវាគាំទ្រកុមាររបស់ភ្នាក់ងារគាំទ្រកុមារក្នុងមូលដ្ឋាន (LCSA) នោះ ក្នុងនោះរាប់បញ្ចូលទាំងការស្វែងរកអ្នកដែលមិនមានសិទ្ធិអាណាព្យាបាលចំពោះកូនរបស់អ្នក (អវត្តមាន) ឬបង្កើតនូវរបបអាណាព្យាបាលសម្រាប់កូន (ច្រើន) របស់អ្នក៖
  - អ្នកត្រូវដឹងថាការស្វែងរកអ្នកដែលមិនមានសិទ្ធិអាណាព្យាបាល និងការបង្កើតរបបអាណាព្យាបាលនឹងអាចជួយអ្នកនាពេលអនាគតក្នុងការប្រមូលប្រាក់ពីការគាំទ្រកុមារ ប្រសិនបើអ្នកត្រូវការវា និង
  - នាពេលអនាគតច្បាប់គាំទ្រកុមារខុសគ្នានឹងត្រូវយកមកអនុវត្ត ប្រសិនបើអ្នកក្លាយខ្លួនជាអ្នកមានលក្ខណៈគ្រប់គាន់សម្រាប់ទទួលជំនួយជាប្រាក់ ។
- អ្នកនឹងរក្សាទុកនូវរាល់លុយគាំទ្រដល់កូនដែលម្តាយ ឬឪពុកដែលមិនបានទំនុកបំរុងកូនឲ្យអ្នក ឬ LCSA បានប្រមូលមកឲ្យអ្នក។ អ្នកមិនចាំបាច់ប្រគល់ប្រាក់ទាំងនោះទៅខោនធីវិញទេ
- ប្រសិនបើអ្នកបើកការប្រើប្រាស់ការទំនុកបំរុងកូនដោយប្រើសេវា LCSA រួចហើយ អ្នកមិនចាំបាច់ធ្វើអ្វីផ្សេងទៀតដើម្បីទំនុកបំរុងកូនរបស់អ្នកនោះទេ ព្រោះកម្មវិធីនេះនឹងប្រមូលឲ្យអ្នក សូមរក្សាទុកនូវចំនួនទឹកប្រាក់នៃការគាំទ្ររបស់កូនដែលអ្នកបានទទួល និងកាលបរិច្ឆេទដែលអ្នកទទួលវា។ អ្នកកចាំបាច់ត្រូវរាយការណ៍រាល់លុយគាំទ្រកូនដែលអ្នកទទួលបានទៅកាន់ខោនធី
- ប្រសិនបើអ្នកមិនបានចុះឈ្មោះបើកការគាំទ្រឲ្យកូនរបស់អ្នកជាមួយនឹង LCSA ទេ នោះអ្នកនឹងត្រូវស្នើសុំសេវាគាំទ្រ កុមារពីភ្នាក់ងារគាំពារកុមារក្នុងមូលដ្ឋាន (LCSA) ដើម្បីឲ្យគេបង្កើតរបបអាណាព្យាបាលសម្រាប់កូនរបស់អ្នក ប្រសិនបើត្រូវការ ហើយឲ្យគេប្រមូលប្រាក់ដែលបានពីការគាំទ្រកូនរបស់អ្នក ហើយផ្ញើប្រាក់នោះមកឲ្យអ្នក។ ខោនធីអាចជួយអ្នកក្នុងការធ្វើវា
- ប្រាក់ដែលបានប្រមូលដោយ LCSA ក្នុងការគាំទ្រកូនរបស់អ្នក និងបានផ្ញើមកឲ្យអ្នកហើយ នឹងមិនត្រូវផ្តល់ជំនួយទៅឲ្យគ្រួសាររបស់អ្នកទៀតទេ ដូច្នេះមនុស្សពេញវ័យដែលទទួលបានសេវា CalWORKs អស់រយៈពេល 48 ខែហើយ គេនឹងចាប់រាប់ជំនួយនេះជាចំនួននៃខវិញ
- នៅពេលអ្នកទទួលបានប្រាក់គាំទ្រកូនរបស់អ្នកដោយផ្ទាល់ អ្នកត្រូវតែរាយការណ៍អំពីប្រាក់ដែលគាំទ្រកូនរបស់អ្នកនោះជាចំណូល ប្រសិនបើច្បាប់ស្តីពីការរាយការណ៍ចំណូលរបស់អ្នកត្រូវឲ្យអ្នកធ្វើដូច្នេះ
- ប្រសិនបើអ្នកទទួលបានចំណូលពីការគាំទ្ររបស់កូនសម្រាប់កូន (ច្រើន) របស់អ្នកនៅលើ CalWORKs យើងនឹងមិនរាប់ប្រាក់ 50 ដុល្លារដំបូងនៅក្នុងខែនីមួយៗទេ។ អ្វីដែលនៅសល់ប្រហែលទូទាត់នឹងជំនួយពី CalWORKs របស់អ្នក
- ប្រសិនបើអ្នកទទួលបានសេវា CalFresh ចំណូលដែលទទួលពីការគាំទ្រកុមារ នឹងត្រូវប្រើប្រាស់ដើម្បីគណនាពីផលប្រយោជន៍ដែលអ្នកទទួលបានពី CalFresh ទាំងមូលផងដែរ។

**ប្រសិនបើអ្នកមានសំណួរអ្វី សូមទូរស័ព្ទទៅខោនធី។**